

ចម្លាក់ស្ដីពីស្ថានសួគ៌ - ជញ្ជាំងប្រាសាទអង្គរវត្ត



ចម្លាក់ស្ដីពីស្ថាននរក - ជញ្ជាំងប្រាសាទអង្គរវត្ត

# សួគ៌ ឬ នរក?

មនុស្ស - សួគ៌ - នរក ពួកដោយឡែក　　ត្រីស្ថានដានចែកបែកទីទៃ
មនុស្សណាសាងបុណ្យគុណប្រពៃ　　ឡើងសួគ៌ាល័យថ្ងៃភពភ័ព្វ។
បើបុណ្យឧត្ដមធំគ្រាន់បើ　　មានគេបម្រើប្រសើរគាប់
តែបើបុណ្យតិចច្បិចមួយជាប់　　មុខក្លាយជាទ័ពចាំផ្គាប់គេ។
មនុស្សណាសាងបាបដាបដោយទោស　　នរកត្រូវចុះមិនខុសទេ
តែបើគន់ដាក់អ្នកនិរយេ　　ឋានៈសក្ដិគេក៏ពីរយ៉ាង។
អ្នកគេធ្វើទុក្ខមុខស្រមេះ　　កាយដាំគ្រាំប្រេះគោលតាងវ៉ាង
តែមួយពួកទៀតមានសំណាង　　ចាំតែរុឹងរ៉ាងធ្វើបាបគេ។
ឡើងឬមួយធ្លាក់ហាក់ដូចគ្នា　　សំខាន់មុខងារជាអ្វីទេ
បើឡើងស្ថានសួគ៌តួខ្ញុំគេ　　មេកងនិរយេគួរគ្នេរអត់?
ស្ដីនេះគ្រាន់ជូនត្រិះពិចារណ៍　　ស្លាប់ហើយទៅណាមិនប្រាកដ
មនុស្សរស់មានធម៌មានបែបបទ　　ជីវិតសន្ទតរស់គាប់ហើយ៕

**ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី**